

ពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការ

# ស្ពានត្សឹបាសា

# SPIEN TSUBASA

( ត្សឹបាសា = ជាភាសាជប៉ុនមានន័យថាស្លាប )

## សម្រាប់កិច្ចសហប្រតិបត្តិការ និង ចំណងទាក់ទងដ៏ស្អិតរមួតរវាង កម្ពុជា និងជប៉ុន

៦ មេសា ២០១៥

From the people of Japan

គម្រោងជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន

# ព័ត៌មានទូទៅ អំពីស្ពាន

| | |
|---|---|
| តម្លៃគម្រោង | ១២៧ លានដុល្លា |
| រយៈពេលសាងសង់ | ខែធ្នូ ឆ្នាំ២០១០ ដល់ ខែមីនា ឆ្នាំ២០១៥ ( ៥១ ខែ ) |
| ប្រវែងស្ពានមេ | ៦៤០ ម៉ែត្រ |
| កម្ពស់បង្គោលសសរមេ | ១២១ ម៉ែត្រ ( គិតពីនីវ៉ូសូន្យ ) |
| កម្ពស់តួស្ពាន | ៣៧,៥ ម៉ែត្រ ( គិតពីនីវ៉ូទឹកអតិប្បរិមា ) |
| ប្រវែងសរុប | ២,២១៥ ម៉ែត្រ |

## ស្ពានត្សឹបាសា

គឺជាស្ពានវែងជាងគេក្នុងប្រទេសកម្ពុជាដែលកាត់ទន្លេមេគង្គតាមបណ្ដោយផ្លូវជាតិលេខ១ ។ ស្ពាននេះ ត្រូវបានសាងសង់ឡើងក្រោមជំនួយឥតសំណងរបស់ជប៉ុនចំនួន ១២៧ លានដុល្លាអាមេរិក ហើយនេះគឺជាជំនួយឥតសំណងដ៏ធំបំផុតរបស់ជប៉ុនទៅកាន់ប្រទេសកម្ពុជា។ ស្ពាននេះត្រូវបានសាងសង់ឡើងតាមរបៀបថ្មីមួយដែលរួមបញ្ចូលបច្ចេកវិទ្យាទំនើបរបស់ជប៉ុនទាំងអស់។ ការបើកឲ្យប្រើប្រាស់នូវស្ពាននេះនឹងជួយលើកស្ទួយគមនាគមន៍ និងការដឹកជញ្ជូនរវាងត្រើយទាំងសងខាងនៃទន្លេ យើងជឿជាក់ថា ការបើកឲ្យប្រើប្រាស់នូវស្ពាននេះនឹងជួយលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា និងតំបន់មេគង្គ។









# ដំណើរការនៃការសាងសង់ស្ពាន

ខែធ្នូ ឆ្នាំ២០១២



ខែកក្កដា ឆ្នាំ២០១៣



ខែសីហា ឆ្នាំ២០១៤





ខែឧសភា ឆ្នាំ២០១៤

ខែមករា ឆ្នាំ២០១៥





ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៥

ពិធីចាក់បេតុងតភ្ជាប់ស្ពាន ត្សឹបាសា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា




ក្រដាសប្រាក់ ៥០០ រៀលថ្មី ដែលមានរចនារូបស្ពានត្សឹបាសា

# ច្រករបៀង សេដ្ឋកិច្ចភាគ **ខាងត្បូង**




ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងតភ្ជាប់រវាងទីក្រុងហូជីមិញ (សាយហ្គន) ប្រទេសវៀតណាម និងទីក្រុងដាវីប្រទេសមីយ៉ាន់ម៉ា ដោយឆ្លងកាត់ភ្នំពេញ និងបាងកក។ នៅប្រទេសកម្ពុជា ផ្លូវជាតិលេខ១ និងលេខ៥ គឺជាផ្នែកមួយនៃច្រករបៀងនេះ។ យើងរំពឹងថាច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងនឹងធ្វើឲ្យការដឹកជញ្ជូនតាមផ្លូវគោកកាន់តែរលូនរវាងប្រទេសកម្ពុជា វៀតណាម ថៃ និងមីយ៉ាន់ម៉ា។ ដូច្នេះ ស្ពានត្សឹបាសា អាចកាត់បន្ថយពេលវេលាធ្វើដំណើរឆ្លងកាត់ទន្លេមេគង្គ និងដោះស្រាយបញ្ហាកំណើននៃតម្រូវការដឹកជញ្ជូននាពេលអនាគត។

**ស្ពានត្សឹបាសា** គឺជាផ្នែកមួយនៃច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង។ រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជួសជុលកែលម្អផ្លូវជាតិលេខ១ និងលេខ៥ ។ ជំនួយឧបត្ថម្ភរបស់ប្រជាជនជប៉ុនសម្រាប់កម្ពុជាមិនត្រឹមតែសម្រាប់ការសាងសង់ផ្លូវថ្នល់ និងស្ពានប៉ុណ្ណោះទេ ប៉ុន្តែក៏មានរួមបញ្ចូលការសាងសង់មន្ទីរពេទ្យ និងសាលារៀន ព្រមទាំងការបញ្ជូនអ្នកជំនាញការសម្រាប់ការកសាងសមត្ថភាពក្នុងវិស័យជាច្រើនផងដែរ។ ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ និងចង់ស្វែងយល់បន្ថែមអំពីជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា សូមចូលមើលគេហទំព័រ៖ http://www.mofa.go.jp/policy/oda/page_000008.html#cambodia

## ព័ត៌មានទូទៅនៃគម្រោង

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងសាងសង់ស្ពានអ្នកលឿងនៅព្រះរាជាណាចក្រកម្ពុជា |
| ក្រសួងអនុវត្តគម្រោង | ក្រសួងសាធារណៈការ និងដឹកជញ្ជូននៃព្រះរាជាណាចក្រកម្ពុជា |
| ក្រុមហ៊ុនម៉ៅការ | ក្រុមហ៊ុនស៊ូមីតូម៉ូ មីតស៊ុយ |
| ទីប្រឹក្សាបច្ចេកទេស | ក្រុមហ៊ុនឆូដៃ និងអូរីអែនថល់ |
| រួមសហការជាមួយ | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន |

©The Embassy of Japan in Cambodia